# ខ និង លក្ខខណ្ឌធានារ៉ាប់រង
# ឈ្មោះផលិតផល៖ "ធានារ៉ាប់រងបន្ថែមសម្រាប់ប្រាក់ឧបត្ថម្ភ សម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ"
# ផលិតផលទី៧របស់ ក្រុមហ៊ុន ជីស៊ី ឡាយហ្វ៍ អ៊ិនសួរេន ម.ក

## 1. គុណលក្ខណៈនៃកិច្ចសន្យាធានារ៉ាប់រង

ខ និង លក្ខខណ្ឌធានារ៉ាប់រងបន្ថែមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ (តទៅហៅថា "កិច្ចសន្យាធានារ៉ាប់រង")។ កិច្ចសន្យានេះមិនអាចបង្កើតចូលជាធរមានដោយខ្លួនឯងឡើយ ហើយវាជាកិច្ចសន្យាធានារ៉ាប់រងបន្ថែមរបស់កិច្ចសន្យាផលិតផលធានារ៉ាប់រងមូលដ្ឋាន។ នៅអំឡុងពេលអនុវត្តន៍កិច្ចសន្យានេះ ប្រសិនបើកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងមូលដ្ឋានត្រូវបានផ្អាកឬបញ្ចប់ កិច្ចសន្យានេះក៏ត្រូវផ្អាកឬបញ្ចប់ទៅតាមកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងមូលដ្ឋានដែរ។

## 2. លក្ខខណ្ឌផ្សេងៗដើម្បីដាក់ពាក្យស្នើសុំ

១. អ្នកស្នើសុំធានារ៉ាប់រងត្រូវជាវនូវផលិតផលធានារ៉ាប់រងមូលដ្ឋានណាមួយខាងក្រោម ដើម្បីដាក់ពាក្យស្នើសុំជាវនូវផលិតផលធានារ៉ាប់រងបន្ថែមសម្រាប់កិច្ចសន្យានេះ។

(១) "គម្រោងការពារខ្លួន"

(២) "គម្រោងអនាគតក្តីសង្ឃឹមបុត្រធីតា"

(៣) "គម្រោងអនាគតភ្លឺស្វាង"

២. អ្នកត្រូវបានធានារ៉ាប់រងត្រូវមានអាយុក្រោម ៦០ឆ្នាំ ព្រមទាំងមានសុខភាពល្អ និងមិនមានជំងឺសតិអារម្មណ៍។

## 3. សមាសភាព ការបង្កើតចូលជាធរមាន និងការមានអនុភាព នៃកិច្ចសន្យាធានារ៉ាប់រង

កិច្ចសន្យានេះបង្កើតឡើងដោយវិញ្ញាបនបត្រធានារ៉ាប់រង ខ និងលក្ខខណ្ឌធានារ៉ាប់រង ពាក្យស្នើសុំធានារ៉ាប់រង និងឯកសារផ្សេងទៀតដែលទាក់ទងនឹងកិច្ចសន្យានេះ។ ឯកសារដែលបានរៀបរាប់ខាងលើអាចចេញជាផ្លូវការដោយឡែក ឬអាចបញ្ចូលជាមួយនឹងឯកសាររបស់កិច្ចសន្យាផលិតផលធានារ៉ាប់រងមូលដ្ឋាន។

នៅពេលអ្នកស្នើសុំធានារ៉ាប់រងដាក់ពាក្យស្នើសុំ និងបានបំពេញបែបបទស្នើសុំធានារ៉ាប់រង ហើយក្រោយពេលក្រុមហ៊ុនយល់ព្រមធានា និងបានផ្តល់ដំណឹងដល់អ្នកស្នើសុំឱ្យបង់បុព្វលាភ កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបានបង្កើត។

ក្រោយពេលកិច្ចសន្យាធានារ៉ាប់រងត្រូវបានបង្កើត បន្ទាប់ពីអ្នកស្នើសុំធានារ៉ាប់រងបានបង់ផ្តាច់បុព្វលាភរបស់កិច្ចសន្យានេះនិងកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងមូលដ្ឋានទាំងអស់ កិច្ចសន្យានេះនឹងកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងមូលដ្ឋាននឹងមានអនុភាពស្របពេលតែមួយ។ នៅពេលកិច្ចសន្យានេះមានអនុភាព ក្រុមហ៊ុនធានារ៉ាប់រងនឹងចេញកិច្ចសន្យាធានារ៉ាប់រងដោយឡែក ឬចេញនូវឯកសារសំខាន់របស់កិច្ចសន្យានេះបញ្ចូលក្នុងកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងមូលដ្ឋានជូនដល់អ្នកស្នើសុំធានារ៉ាប់រងភ្លាម។

## 4. រយៈពេលធានារ៉ាប់រង

រយៈពេលធានារ៉ាប់រងនៃកិច្ចសន្យានេះ មានរយៈពេល១ឆ្នាំ។

## 5. ការស្នើសុំបន្តធានារ៉ាប់រង

១. នៅពេលដែលរយៈពេលធានារ៉ាប់រងនៃកិច្ចសន្យានេះត្រូវបានបញ្ចប់ អ្នកស្នើសុំធានារ៉ាប់រងអាចធ្វើការស្នើសុំបន្តធានារ៉ាប់រងបាន។ អ្នកស្នើសុំត្រូវធ្វើការស្នើសុំបន្តធានារ៉ាប់រង ព្រមទាំងបង់បុព្វលាភទាំងអស់ នៅពេលដែលរយៈពេលធានារ៉ាប់រងជិតបានបញ្ចប់ ឬនៅថ្ងៃដែលកិច្ចសន្យានេះត្រូវបានបញ្ចប់ ទើបអាចតភ្ជាប់រយៈពេលធានារ៉ាប់រងបាន ពុំនោះទេមិនអាចតភ្ជាប់រយៈពេលធានារ៉ាប់រងបានឡើយ។ ប្រសិនបើមានព្រឹត្តិការណ៍ស្ថិតក្រោមវិសាលភាពនៃការធានាកើតឡើងនៅចន្លោះពេលរវាងរយៈពេលធានារ៉ាប់រងដល់កាលកំណត់ និងរយៈពេលបន្តធានារ៉ាប់រងចាប់ផ្តើមមានសុពលភាព ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានទំនួលខុសត្រូវទៅលើវិសាលភាពនៃការធានារបស់កិច្ចសន្យានេះឡើយ។

## 6. បុព្វលាភធានារ៉ាប់រង អតិបរមានៃសំណងធានារ៉ាប់រង និងការកំណត់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យ

បុព្វលាភធានារ៉ាប់រង អតិបរមានៃសំណងធានារ៉ាប់រង និងការកំណត់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យក្នុងកិច្ចសន្យានេះ សមាមាត្រទៅនឹងតារាងខាងក្រោម ក្នុងនោះបែងចែកជា ៤គម្រោងរួមមាន A B C D។ អ្នកស្នើសុំអាចធ្វើការជ្រើសរើសគម្រោងណាមួយក្នុងចំណោមនោះ តាមការកំណត់ដូចខាងក្រោម:

១. ប្រសិនបើកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងមូលដ្ឋានគឺជា "គម្រោងការពារខ្លួន" ហើយបុព្វលាភប្រចាំឆ្នាំនៃកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងមូលដ្ឋានទាបជាង ៥០ដុល្លារសហរដ្ឋអាមេរិក នោះអ្នកស្នើសុំមិនអាចជ្រើសរើសគម្រោង C និង Dឡើយ។

២. ប្រសិនបើកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងមូលដ្ឋានគឺជា "គម្រោងអនាគតក្តីសង្ឃឹមបុត្រធីតា" ឬ "គម្រោងអនាគតភ្លឺស្វាង" នោះអ្នកស្នើសុំអាចជ្រើសរើសគម្រោងណាមួយក្នុងចំណោមគម្រោងទាំង ៤ខាងលើ។

**បុព្វលាភធានារ៉ាប់រង អតិបរមានៃសំណងធានារ៉ាប់រង និងការកំណត់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យ**

រូបិយបណ្ណ : ដុល្លារសហរដ្ឋអាមេរិក

| គម្រោង | បុព្វលាភធានារ៉ាប់រង | អតិបរមានៃសំណងធានារ៉ាប់រង | ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ | ចំនួនថ្ងៃផ្តល់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យក្នុងមួយលើក | ចំនួនថ្ងៃបូកសរុបក្នុងការផ្តល់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យប្រចាំឆ្នាំ |
|---|---|---|---|---|---|
| A | 4 | 480 | 8 | 30 | 60 |
| B | 8 | 1200 | 12 | 50 | 100 |
| C | 16 | 2880 | 16 | 80 | 180 |
| D | 36 | 6600 | 30 | 100 | 220 |

## 7. វិសាលភាពនៃការធានា

នៅក្នុងអំឡុងពេលដែលកិច្ចសន្យាធានារ៉ាប់រងមានអនុភាព ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងជួបគ្រោះថ្នាក់ជាយថាហេតុ ហើយត្រូវបានចូលសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលស្របច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជាដោយសារគ្រោះថ្នាក់នោះ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យតាមការព្រមព្រៀងខាងក្រោម:

១. ចំពោះវិធីសាស្ត្រគណនាប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យ ត្រូវផ្អែកតាមចំនួនថ្ងៃសម្រាកនៅមន្ទីរពេទ្យជាក់ស្តែងរបស់អ្នកត្រូវបានធានារ៉ាប់រងដោយដកចេញ ៣ថ្ងៃដំបូង រួចយកចំនួនថ្ងៃដែលនៅសល់ គុណនឹងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃដែលសមាមាត្រទៅនឹងគម្រោងនីមួយៗក្នុងតារាងខាងលើ។

២. ចំពោះការកំណត់ចំនួនថ្ងៃផ្តល់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យក្នុងមួយលើករបស់អ្នកត្រូវបានធានារ៉ាប់រង: ត្រូវអនុវត្តន៍តាម "ចំនួនថ្ងៃផ្តល់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យក្នុងមួយលើក" ដែលសមាមាត្រគ្នាទៅនឹងគម្រោងនីមួយៗក្នុងតារាងខាងលើ។ ប្រសិនបើមូលហេតុនៃការសម្រាកនៅមន្ទីរពេទ្យរបស់អ្នកត្រូវបានធានារ៉ាប់រងបច្ចុប្បន្ន ដូចគ្នាទៅនឹងការសម្រាកនៅមន្ទីរពេទ្យលើកមុន ហើយរយៈពេលដែលចេញពីមន្ទីរពេទ្យលើកមុន និងការចូលសម្រាកនៅមន្ទីរពេទ្យនាពេលបច្ចុប្បន្នមានគម្លាតរយៈពេលតិចជាង៣០ថ្ងៃ នោះការសម្រាកនៅមន្ទីរពេទ្យនាពេលបច្ចុប្បន្ន និងការសម្រាកនៅមន្ទីរពេទ្យលើកមុនត្រូវបានចាត់ទុកថាជាការសម្រាកនៅមន្ទីរពេទ្យតែមួយលើក។

៣. ចំពោះការកំណត់ចំនួនថ្ងៃផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការសម្រាកនៅមន្ទីរពេទ្យក្នុងមួយឆ្នាំរបស់អ្នកត្រូវបានធានារ៉ាប់រង: ត្រូវអនុវត្តន៍តាម "ចំនួនថ្ងៃបូកសរុបក្នុងការផ្តល់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យប្រចាំឆ្នាំ" ដែលសមាមាត្រគ្នាទៅនឹងគម្រោងនីមួយៗក្នុងតារាងខាងលើ។ ប្រសិនបើមានគ្រោះថ្នាក់ជាយថាហេតុកើតឡើងក្នុង

រយៈពេលធានារ៉ាប់រង ហើយអ្នកត្រូវបានធានារ៉ាប់រងនៅតែបន្តសម្រាកព្យាបាលនៅមន្ទីរពេទ្យក្រោយពេលដែលរយៈពេលធានារ៉ាប់រងត្រូវបានបញ្ចប់ ដរាបណារយៈពេលធានារ៉ាប់រងបានបញ្ចប់មិនទាន់ដល់គម្រប់ខួប ១ឆ្នាំ ក្រុមហ៊ុនធានារ៉ាប់រងនៅតែបន្តផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការសម្រាកនៅមន្ទីរពេទ្យ ប៉ុន្តែចំនួនថ្ងៃបូកសរុបផ្តល់ប្រាក់ឧបត្ថម្ភទាំងក្នុងរយៈពេលធានារ៉ាប់រង និងក្រោយរយៈពេលធានារ៉ាប់រងត្រូវបានបញ្ចប់ នៅតែកំណត់តាម "ចំនួនថ្ងៃបូកសរុបក្នុងការផ្តល់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យប្រចាំឆ្នាំ"ដែលសមាមាត្រគ្នាទៅនឹងគម្រោងនីមួយៗក្នុងតារាងខាងលើដដែរ។

## 8. ករណីលើកលែង

១. ការចំណាយក្នុងការព្យាបាលជំងឺរបស់អ្នកត្រូវបានធានារ៉ាប់រង ព្រមទាំងការថែសម្ផស្ស ថែទាំធ្មេញឬព្យាបាលធ្មេញ រួមមានការសម្អាតធ្មេញ ការធ្វើឲ្យធ្មេញស ពុតធ្មេញ ដាក់ធ្មេញសេរ៉ាមិច ការវះកាត់ដាក់បង្គោលធ្មេញ ឬការព្យាបាលធ្មេញធម្មតាដែលមិនស្ថិតក្រោមវិសាលភាពនៃការធានារបស់កិច្ចសន្យា ក្រុមហ៊ុននឹងមិនមានកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រងឡើយ។

២. អ្នកត្រូវបានធានារ៉ាប់រង សម្រាកនៅមន្ទីរពេទ្យក្រៅប្រទេសកម្ពុជា។

៣. ក្រុមហ៊ុនធានារ៉ាប់រងមិនមានកាតព្វកិច្ចផ្តល់នូវប្រាក់ឧបត្ថម្ភសម្រាប់ការសម្រាកនៅមន្ទីរពេទ្យឡើយ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងសម្រាកនៅមន្ទីរពេទ្យដោយសារតែព្រឹត្តិការណ៍ណាមួយដូចខាងក្រោម÷

(1) អ្នកត្រូវបានធានារ៉ាប់រងស្នើសុំធានារ៉ាប់រងទាំងខ្លួនមានជំងឺ ហើយនៅពេលដែលអ្នកស្នើសុំធានារ៉ាប់រងបំពេញបែបបទស្នើសុំ មិនបានប្រាប់នូវការពិតនៃស្ថានភាពជំងឺនោះ

(2) អ្នកស្នើសុំធានារ៉ាប់រងមានចេតនាធ្វើឃាត ឬបង្ករបួសទៅលើអ្នកត្រូវបានធានារ៉ាប់រង

(3) អ្នកត្រូវបានធានារ៉ាប់រងបានប្រព្រឹត្តបទល្មើស ឬប្រឆាំងនឹងវិធានការបង្ខិតបង្ខំណាមួយតាមផ្លូវច្បាប់

(4) អ្នកត្រូវបានធានារ៉ាប់រងធ្វើអត្តឃាត ឬបង្ករបួសលើខ្លួនឯងដោយចេតនា លើកលែងតែនៅពេលធ្វើអត្តឃាត ឬបង្ករបួសលើខ្លួនឯងនោះ អ្នកត្រូវបានធានារ៉ាប់រងបានបាត់បង់សមត្ថភាពផ្នែកស៊ីវិលរបស់ខ្លួនដែលកំណត់ដោយច្បាប់ព្រះរាជាណាចក្រកម្ពុជា

(5) អ្នកត្រូវបានធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការវាយតប់គ្នា ឬការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន

(6) អ្នកត្រូវបានធានារ៉ាប់រងបើកបរក្នុងស្ថានភាពស្រវឹង បើកបរក្នុងស្ថានភាពគ្រោះថ្នាក់ បើកបរដោយគ្មានបណ្ណបើកបរត្រឹមត្រូវ ឬបើកបរយានយន្តដោយគ្មានការចុះបញ្ជីត្រឹមត្រូវដែលបានកំណត់ដោយច្បាប់

(7) អ្នកត្រូវបានធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការជ្រមុជទឹក ការលោតឆ័ត្រយោង ការឡើងភ្នំ ការផ្សងព្រេង ការសម្តែងបច្ចេកទេសពិសេស ការប្រណាំងរថយន្ត

(8) ការពិនិត្យមុន និងក្រោយមានផ្ទៃពោះ ការមានផ្ទៃពោះ (រួមមានកូនក្រៅស្បូន) ការរលូតកូន (រួមទាំងការរំលូតកូន) ការសម្រាលកូន (រួមទាំងការសម្រាលកូនដោយវះកាត់) ការពន្យារកំណើត ការវះកាត់មិនឲ្យមានកូន ការព្យាបាលឲ្យមានកូន និងជំងឺផ្សេងទៀតដែលវិវឌ្ឍន៍ចេញពីជំងឺខាងលើនេះរបស់អ្នកស្នើសុំ ឬអ្នកត្រូវបានធានារ៉ាប់រង ដែលបណ្តាលអោយកើតមានគ្រោះថ្នាក់ស្ថិតក្រោមវិសាលភាពនៃការធានាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ

(9) អ្នកត្រូវបានធានារ៉ាប់រងខកខានមិនបានអនុវត្តតាមវេជ្ជបញ្ជាវេជ្ជសាស្ត្រ ហើយប្រើប្រាស់ ឬលេបថ្នាំដោយខ្លួនឯង (លើកលែងតែការប្រើប្រាស់ថ្នាំតាមវេជ្ជបញ្ជា ដោយយោងតាមការណែនាំសម្រាប់ការប្រើប្រាស់)

(10) អ្នកត្រូវបានធានារ៉ាប់រងទទួលរងនូវឧប្បត្តិហេតុខាងវេជ្ជសាស្ត្រ ដោយសារការវះកាត់កែសម្ផស្ស ឬការវះកាត់ផ្សេងៗ

(11) អ្នកត្រូវបានធានារ៉ាប់រងមានជំងឺសតិអារម្មណ៍ ឬអាកប្បកិរិយាមិនប្រក្រតី

(12) សង្គ្រាម ការប៉ះទង្គិចផ្នែកយោធា ការបះបោរ ឬការបះបោរប្រដាប់អាវុធ

(13) ការផ្ទុះនុយក្លេអ៊ែរវិទ្យុសកម្មនុយក្លេអ៊ែរ ឬការចម្លងរោគពីនុយក្លេអ៊ែរ

## 9. អ្នកទទួលផល

អ្នកត្រូវបានធានារ៉ាប់រង ដូចមានបញ្ជាក់នៅក្នុងកិច្ចសន្យានេះ គឺជាអ្នកទទួលផលនៃកិច្ចសន្យាធានារ៉ាប់រង។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅក្នុងអំឡុងពេលឬក្រោយពេលសម្រាកនៅមន្ទីរពេលទទួលមរណភាព នោះនឹងតម្រូវឲ្យអ្នកទទួលផលរបស់កិច្ចសន្យាផលិតផលធានារ៉ាប់រងមូលដ្ឋានធ្វើការទាមទារសំណងធានារ៉ាប់រង។

## 10. ការជូនដំណឹងអំពីព្រឹត្តិការណ៍ស្ថិតក្រោមវិសាលភាពនៃការធានា

នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងសម្រាកនៅមន្ទីរពេទ្យដោយសារគ្រោះថ្នាក់ជាយថាហេតុ អ្នកស្នើសុំធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬសាច់ញាតិរបស់អ្នកត្រូវបានធានារ៉ាប់រងបានដឹងពីព្រឹត្តិការណ៍ស្ថិតក្រោមវិសាលភាពនៃការធានាណាមួយ ត្រូវជូនដំណឹងឲ្យក្រុមហ៊ុនធានារ៉ាប់រងឲ្យបានទាន់ពេល ឬក្នុងរយៈពេលយ៉ាងយូរ៥ថ្ងៃ ព្រមទាំងជួយសម្រួលដល់បុគ្គលិករបស់ក្រុមហ៊ុនធានារ៉ាប់រងដើម្បីទៅសួរសុខទុក្ខអ្នកត្រូវបានធានារ៉ាប់រងនៅមន្ទីរពេទ្យឲ្យបានទាន់ពេលវេលា។ ប្រសិនបើមានចេតនាមិនជូនដំណឹងដល់ក្រុមហ៊ុនឲ្យបានទាន់ពេល បណ្តាលឲ្យក្រុមហ៊ុនធានារ៉ាប់រងអលទ្ធភាពក្នុងការកំណត់អំពីមូលហេតុកម្រិតខូចខាត និងលក្ខណៈឧបទ្ទវហេតុនោះ ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានកាតព្វកិច្ចទូទាត់សំណងធានារ៉ាប់រងសម្រាប់ផ្នែកណាមួយដែលខ្លួនមិនអាចកំណត់បានទេ លើកលែងតែ ក្រុមហ៊ុនធានារ៉ាប់រងបានដឹងពីស្ថានភាពនៃឧបទ្ទវហេតុនោះតាមរយៈមធ្យោបាយផ្សេងទៀត។

នៅក្នុងអំឡុងពេលដែលអ្នកត្រូវបានធានារ៉ាប់រងសម្រាកនៅមន្ទីរពេទ្យ អ្នកស្នើសុំធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬសាច់ញាតិរបស់អ្នកត្រូវបានធានារ៉ាប់រងត្រូវប្រមូលភស្តុតាងពីមន្ទីរពេទ្យ និងរក្សាភស្តុតាងទុកដើម្បីបញ្ជាក់ឲ្យបានច្បាស់ថាអ្នកត្រូវបានធានារ៉ាប់រងបានទទួលរងគ្រោះថ្នាក់ជាយថាហេតុ និងដើម្បីផ្តល់ឲ្យក្រុមហ៊ុនធានារ៉ាប់រង នៅពេលដែលខ្លួនទាមទារសំណងធានារ៉ាប់រង ដើម្បីបញ្ជាក់ពីការកើតហេតុនៃគ្រោះថ្នាក់ជាយថាហេតុនោះ ស្ថានភាពនៃការរងរបួសការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងចំនួនថ្ងៃនៃការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ នៅពេលដែលខ្លួនបានដឹងអំពីគ្រោះថ្នាក់ដែលបានកើតឡើង។

## 11. ការទាមទារ និងការទូទាត់សំណង

១. អ្នកទាមទារសំណង ត្រូវបំពេញបែបបទស្នើសុំទាមទារសំណង និងផ្តល់ភស្តុតាងបញ្ជាក់ ព្រមទាំងឯកសារតម្រូវផ្សេងៗទៀតសម្រាប់ការទាមទារសំណង ដូចដែលមានចែងនៅក្នុងប្រការ ១២ នៃកិច្ចសន្យានេះ។ អ្នកទាមទារសំណងត្រូវមានកាតព្វកិច្ចផ្តល់នូវភស្តុតាងពាក់ព័ន្ធ និងឯកសារដែលបានបញ្ជាក់ផ្សេងៗឲ្យបានឆាប់រហ័ស។

២. នៅពេលទទួលសំណុំបែបបទស្នើសុំទាមទារសំណង និងភស្តុតាងបញ្ជាក់ ក៏ដូចជាឯកសារដូចដែលបានបញ្ជាក់ខាងលើនេះ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្ទៀងផ្ទាត់ក្នុងរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការ ឬ២០ថ្ងៃនៃថ្ងៃធ្វើការសម្រាប់ករណីស្មុគស្មាញ ហើយក្រុមហ៊ុននឹងជូនដំណឹងទៅកាន់អ្នកទាមទារសំណង អំពីស្ថានភាពវិវត្តន៍នៃដំណើរការទាមទារសំណង។

បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់រួច ប្រសិនបើត្រូវបានបញ្ជាក់ថាត្រូវធ្វើការទូទាត់សង នោះក្រុមហ៊ុនធានារ៉ាប់រងនឹងទូទាត់សំណងក្នុងរយៈពេល២ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានព្រមព្រៀងគ្នាជាមួយអ្នកទាមទារសំណងលើការទូទាត់សំណងនេះ។

បន្ទាប់ពីពិនិត្យផ្ទៀងផ្ទាត់រួចហើយ ប្រសិនបើត្រូវបានបញ្ជាក់ថាមិនត្រូវធ្វើការទូទាត់សងទេនោះ ក្រុមហ៊ុនធានារ៉ាប់រងនឹងចេញលិខិតជូនដំណឹងមួយស្តីពីការបដិសេធក្នុងការទូទាត់សំណងធានារ៉ាប់រងទៅឲ្យអ្នកដាក់ពាក្យទាមទារសំណងក្នុងរយៈពេល ២ ថ្ងៃនៃថ្ងៃធ្វើការដោយមានការពន្យល់បញ្ជាក់អំពីមូលហេតុពីការបដិសេធនោះផងដែរ។

៣. រយៈពេលមានប្រសិទ្ធភាពសម្រាប់អ្នកទទួលផលដើម្បីទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រងនេះ គឺមានរយៈពេល១ ឆ្នាំ គិតចាប់ពីថ្ងៃដែលអ្នកទទួលផលបានដឹង ឬគួរដឹងអំពីគ្រោះថ្នាក់នោះ។

## 12. ភស្តុតាង និងឯកសារតម្រូវសម្រាប់ការទាមទារសំណងធានារ៉ាប់រង

១. កិច្ចសន្យាធានារ៉ាប់រង ឬភស្តុតាងផ្សេងទៀតដែលបង្ហាញថាកិច្ចសន្យាធានារ៉ាប់រងនៅមានអនុភាព

២. ឯកសារបញ្ជាក់អត្តសញ្ញាណស្របច្បាប់ ដែលមានសុពលភាពរបស់អ្នកទាមទារសំណង

៣. ភស្តុតាង និងឯកសារដែលបង្ហាញពីអង្គហេតុ លក្ខណៈដើម និងមូលហេតុនៃគ្រោះថ្នាក់ជាយថាហេតុ ព្រមទាំងភស្តុតាង និងឯកសារដែលបង្ហាញពីការសម្រាកព្យាបាលនៅមន្ទីរពេទ្យដែលនឹងត្រូវផ្តល់ឲ្យក្រុមហ៊ុនធានារ៉ាប់រងដោយអ្នកទាមទារសំណងរួមមានៈ

(១)លិខិតបញ្ជាក់ការចូលសម្រាកនៅមន្ទីរពេទ្យ លិខិតបញ្ជាក់ពីរោគវិនិច្ឆ័យនៃការរងរបួសដោយថៃជន្យ(រួមបញ្ចូលទាំងមូលដ្ឋានរោគវិនិច្ឆ័យ) កំណត់ត្រាសម្រាកនៅមន្ទីរពេទ្យ និងភស្តុតាងចាំបាច់ផ្សេងទៀតដែលបញ្ជាក់ពីការកើតឡើងនូវគ្រោះថ្នាក់ កម្រិតនៃការរងរបួស និងការពិត និងចំនួនថ្ងៃនៃការចូលសម្រាកនៅមន្ទីរពេទ្យដែលចេញដោយមន្ទីរពេទ្យដែលអ្នកត្រូវបានធានារ៉ាប់រងសម្រាកព្យាបាល។

(២)អំឡុងពេលដែលអ្នកត្រូវបានធានារ៉ាប់រងសម្រាកនៅមន្ទីរពេទ្យ តម្រូវឲ្យអ្នកស្នើសុំធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង អ្នកទទួលផល ឬសាច់ញាតិរបស់អ្នកត្រូវបានធានារ៉ាប់រង ថតរូប ឬថតវីឌីអូបញ្ជាក់ពីការសម្រាកនៅមន្ទីរពេទ្យ និងចំនួនថ្ងៃចូលសម្រាកនៅមន្ទីរពេទ្យរបស់អ្នកត្រូវបានធានារ៉ាប់រង។

(៣)ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងទទួលបាននូវឯកសាររបស់អ្នកទាមទារសំណងដូចបានរៀបរាប់ខាងលើ ហើយនៅតែមិនអាចផ្ទៀងផ្ទាត់បាន ក្រុមហ៊ុនមានសិទ្ធិស្នើឲ្យអ្នកទាមទារសំណងផ្តល់នូវឯកសារបន្ថែមឲ្យបានគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីការពិតនៃគ្រោះថ្នាក់ជាយថាហេតុនោះ ពេលវេលាគ្រោះថ្នាក់ និងឯកសារផ្សេងទៀតដែលបញ្ជាក់អំពីការពិតនៃការសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

៤. ប្រសិនបើមានអ្នកតំណាងត្រូវបានតែងតាំងដើម្បីទាមទារប្រាក់សំណង ត្រូវផ្តល់បន្ថែមនូវលិខិតផ្ទេរសិទ្ធិតំណាង និងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកតំណាង។

## 13. **ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រងដោយអ្នកស្នើសុំធានារ៉ាប់រង**

បន្ទាប់ពីកិច្ចសន្យាធានារ៉ាប់រងត្រូវបានបង្កើត អ្នកស្នើសុំធានារ៉ាប់រងអាចស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងបាន លើកលែងតែមានការព្រមព្រៀងផ្សេងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមានការទូទាត់សំណងណាមួយ ឬមានឧបទ្ទវហេតុណាមួយកើតឡើងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងតែសំណងមិនទាន់ត្រូវបានទូទាត់ អ្នកស្នើសុំធានារ៉ាប់រងមិនអាចស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងបានទេ។ ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រង នាង/គាត់ត្រូវបំពេញទម្រង់បែបបទស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រង និងប្រគល់កិច្ចសន្យាធានារ៉ាប់រង ព្រមទាំងលិខិតបញ្ជាក់អត្តសញ្ញាណរបស់អ្នកស្នើសុំធានារ៉ាប់រងផងដែរ។ កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបញ្ចប់នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងទទួលបានសំណើសុំបញ្ចប់កិច្ចសន្យា។ ក្នុងរយៈពេល២ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលក្រុមហ៊ុនធានារ៉ាប់រងទទួលបានសំណើបញ្ចប់កិច្ចសន្យា ក្រុមហ៊ុននឹងអនុលោមតាមតារាងឧបសម្ព័ន្ធ 《តារាងផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រងសម្រាប់ "ធានារ៉ាប់រងបន្ថែមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ"》 ដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រងមួយចំនួនជូនទៅកាន់អ្នកស្នើសុំវិញ ហើយកិច្ចសន្យានឹងត្រូវបញ្ចប់។

## 14. **ការផ្លាស់ប្តូរអាជីព ឬការងារ**

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងផ្លាស់ប្តូរអាជីព ឬការងាររបស់ខ្លួន អ្នកស្នើសុំធានារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងទៅក្រុមហ៊ុនធានារ៉ាប់រងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ថ្ងៃ ពុំនោះទេនឹងអាចបណ្តាលឲ្យកិច្ចសន្យាធានារ៉ាប់រងបាត់បង់នូវអនុភាព។

បន្ទាប់ពីអ្នកត្រូវបានធានារ៉ាប់រងបានផ្លាស់ប្តូរអាជីព ឬការងាររបស់ខ្លួន ហើយកម្រិតនៃហានិភ័យកើនឡើងជាក់ស្តែង ក្រុមហ៊ុនធានារ៉ាប់រងសូមរក្សាសិទ្ធិបង្កើនប្រាក់បុព្វលាភ័ភ្លាមចំពោះអ្នកស្នើសុំធានារ៉ាប់រង។ ប្រសិនបើកម្រិតនៃហានិភ័យគឺមានកម្រិតខ្ពស់ខ្លាំង ហើយលក្ខណៈការងាររបស់គាត់ត្រូវបានផ្ទៀងផ្ទាត់ថាជាការងារមួយដែលមិនអាចធានាបាន ក្រុមហ៊ុនធានារ៉ាប់រងសូមរក្សាសិទ្ធិបញ្ចប់កិច្ចសន្យាធានារ៉ាប់រង រួចក្រុមហ៊ុននឹងអនុលោមតាមតារាងឧបសម្ព័ន្ធ 《តារាងផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រងសម្រាប់ "ធានារ៉ាប់រងបន្ថែមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ"》 ដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រងមួយចំនួនជូនទៅកាន់អ្នកស្នើសុំវិញ ហើយកិច្ចសន្យានឹងត្រូវបញ្ចប់។

## 15. **ការពន្យល់ និងការបង្ហាញពត៌មានពិត**

នៅពេលអនុវត្តកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងត្រូវពន្យល់អ្នកស្នើសុំធានារ៉ាប់រងឲ្យបានច្បាស់អំពី ខ្លឹមសារនៃកិច្ចសន្យាធានារ៉ាប់រង។ ចំពោះករណីលើកលែងដែលមានចែងនៅក្នុង ខ និងលក្ខខណ្ឌផ្សេងៗនៃកិច្ចសន្យាធានារ៉ាប់រង នៅពេលបង្កើតកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នៅលើពាក្យស្នើសុំធានារ៉ាប់រង កិច្ចសន្យាធានារ៉ាប់រង ឬឯកសារធានារ៉ាប់រងផ្សេងទៀតដើម្បីឲ្យអ្នកស្នើសុំធានារ៉ាប់រងមានការប្រុងប្រយ័ត្ន។

ក្រុមហ៊ុនធានារ៉ាប់រងអាចធ្វើការសាកសួរអំពីស្ថានភាពរបស់អ្នកស្នើសុំធានារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ហើយអ្នកស្នើសុំធានារ៉ាប់រងត្រូវជូនដំណឹងឲ្យបានច្បាស់ដល់ក្រុមហ៊ុនធានារ៉ាប់រង ។

ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងមិនបានបំពេញកាតព្វកិច្ចស្តីពីការជូនដំណឹងពិត ដូចមានចែងក្នុងកថាខណ្ឌខាងមុខតាមរយៈការលាក់បាំង ឬកុហកដោយចេតនាដែលជាលទ្ធផលបណ្តាលឲ្យក្រុមហ៊ុនធានារ៉ាប់រងមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការសម្រេចថាតើត្រូវធានា ឬត្រូវបង្កើនអត្រាបុព្វលាភ ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិបញ្ចប់កិច្ចសន្យា រួចក្រុមហ៊ុននឹងអនុលោមតាមតារាងឧបសម្ព័ន្ធ 《តារាងផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រងសម្រាប់ "ធានារ៉ាប់រងបន្ថែមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ"》 ដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រងមួយចំនួនជូនទៅកាន់អ្នកស្នើសុំវិញ ហើយកិច្ចសន្យានឹងត្រូវបញ្ចប់។

## 16. **ការដោះស្រាយវិវាទ**

ចំពោះគ្រប់វិវាទដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្មឬតុលាការមានសមត្ថកិច្ច លើកលែងតែរឿងព្រហ្មទណ្ឌ។

## 17. **ភាសា**

កិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានប្រើប្រាស់ជាភាសាខ្មែរ ហើយក៏អាចផ្តល់ជូនជាភាសាអង់គ្លេស និងភាសាចិនផងដែរ ប៉ុន្តែក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយកភាសាខ្មែរជាគោល។

## 18. **ផ្សេងៗ**

ប្រសិនបើមានផ្នែកណាមួយមិនច្បាស់លាស់ សូមអាន ខ និង លក្ខខណ្ឌ នៃកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងមូលដ្ឋានសម្រាប់ពត៌មានលម្អិត។

## 19. **តារាងឧបសម្ព័ន្ធ** 《តារាងផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រងសម្រាប់ "ធានារ៉ាប់រងបន្ថែមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ"》

រូបិយបណ្ណ÷ ដុល្លារសហរដ្ឋអាមេរិក

| គម្រោង / ប្រចាំខែ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| A | 2.38 | 2.17 | 1.95 | 1.73 | 1.52 | 1.30 | 1.08 | 0.87 | 0.65 | 0.43 | 0.22 | 0 |
| B | 4.77 | 4.33 | 3.90 | 3.47 | 3.03 | 2.60 | 2.17 | 1.73 | 1.30 | 0.87 | 0.43 | 0 |
| C | 9.53 | 8.67 | 7.80 | 6.93 | 6.07 | 5.20 | 4.33 | 3.47 | 2.60 | 1.73 | 0.87 | 0 |
| D | 21.45 | 19.5 | 17.55 | 15.6 | 13.65 | 11.7 | 9.75 | 7.8 | 5.85 | 3.9 | 1.95 | 0 |

**បញ្ជាក់:** ពាក្យ "ប្រចាំខែ" នៅក្នុងតារាងខាងលើនេះ គឺបង្ហាញអំពីចំនួនខែដែលបានកន្លងផុតទៅនៅពេលដែលកិច្ចសន្យាត្រូវបានបញ្ចប់ដោយសារមូលហេតុណាមួយក្នុងរយៈពេលធានារ៉ាប់រង។ ប្រសិនបើមិនទាន់គ្រប់១ខែ ត្រូវយកចំនួន១ខែមកគិត។ ឧទាហរណ៍: កិច្ចសន្យាធានារ៉ាប់រងត្រូវបានឆ្លងកាត់ចំនួន២ខែ ១៣ថ្ងៃ នោះត្រូវយកចំនួន៣ខែមកគិត។